# ក្រុមស្ត្រីសហគមន៍ដូនតោក

## សំណង់បង្គន់ ឆ្នាំ២០០៩

**ខែកុម្ភៈ:** សមាគមធាងត្នោត ជួបជាមួយសហគមន៍ និង ធ្វើកម្មវិធីថតរូបសហគមន៍ជាបីក្រុម (ក្រុមស្ត្រី, បុរស និង កុមារ) ដើម្បីស្វែងរកអ្វីដែលពួកគេចូលចិត្ត និង មិនចូលចិត្តក្នុងសហគមន៍។




**ខែមេសា:** ក្រុមស្ត្រីសំរេចចិត្តថា ពួកគាត់ត្រូវការសាងសង់បង្គន់សាធារណៈដើម្បីធ្វើអោយផ្នែកអនាម័យក្នុងភូមិមានភាពប្រសើរឡើង ។ពួកគាត់ពិភាក្សាពីគំរោងសាងសង់ តំលៃ និងចំនួនបដិភាគចូលរួម ពីពួកគាត់ដើម្បីធ្វើបង្គន់អនាម័យនេះ ។នៅក្នុងខែមិថុនាដែលជារដូវវស្សា គំរោងទាំងនេះក៏ស្ថិតក្នុង ការរង់ចាំ។

**ខែតុលា:** ក្រុមស្ត្រីយល់ព្រមចេញបដិភាគដូចជា ឈើ, ខ្សាច់ និង ឈ្នួលកម្មករ ដើម្បីសង់បង្គន់។ ពួកគាត់បានប្រមូលវិភាគទានបាន ២៥ ដុល្លារ ។ បួងចុងក្រោយត្រូវបានចេញជាបង្គន់អនាម័យ២ ក្នុងតំលៃប្រហែល ៣៣៥ ដុល្លារ ។

**ខែធ្នូ:** ការសាងសង់រួចរាល់បានដោយមានបន្ថែមថ្លៃឈ្នួលជាង, បន្ថែមសំភារៈ និង ថ្លៃផ្សេងៗទៀតប៉ុន្តែ..........

---

| | **ទឹកប្រាក់គំរោង** | **ទឹកប្រាក់បានចំណាយ** |
|---|---|---|
| តំលៃសាងសង់ | ២៤៥ | ២៩៤ |
| ថ្លៃឈ្នួលកម្មករ | ០ | ១០០ |
| បដិភាគសហគមន៍ចូលរួម | | |
| ខ្សាច់ | ២០ | ២០ |
| ឈើ | ៤០ | ៤០ |
| ថ្លៃឈ្នួលកម្មករ | ៣០ | ០ |
| **សរុប** | **៣៣៥** | **៤៥៤** |

សមាគមន៏ផាងត្នោត(STT)បានចូលរួមបដិភាគ ៣៧៤ ដុល្លារ និង អង្គការ CWDCC បានចូលរួម ២០ដុល្លារ និង ជួយតទឹក ។ សូមអរគុណយ៉ាងខ្លាំងផងដែរ ចំពោះក្រុមប្រឹក្សាឃុំត្រើយកោះ សំរាប់ការគាំទ្រ និង ការជួយរបស់ពួកគាត់ ។




**រូបខាងស្តាំ:** STT ចេញប្លង់ដោយផ្អែកលើការពិភាក្សារបស់ក្រុមស្ត្រី

**រូបខាងក្រោម:** កន្លែងសាង់សង់ស្ថិតនៅចន្លោះដើមដូង ដែលផ្តល់ម្លប់ដ៏ត្រជាក់ និង ខ្យល់ដ៏ល្អ ។





**រូបភាពខាងលើ:** ការសាង់សង់ជិតរួចរាល់ហើយ ។ ជញ្ជាំងស័ង្កសីត្រូវបានជំនួសដោយ ឥដ្ឋ រួមទាំង ការស្នើសុំចាក់សាបជុំវិញបង្គន់ ដើម្បីកុំអោយច្រំនៅរដូវវស្សា ដែលធ្វើអោយលើសថវិការដែលមាន ។